**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៦៦៩ ...សហវ....ទស

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០១១

**គោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម**

**កម្មវត្ថុ:** សំណើសុំជានាចំណាយថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» ចំនួន ១ ៣២៨ ៤១០ ៨៩៤ រៀល ជូននាយកដ្ឋានវិស្វកម្មក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់ការងារជួសជុលឡើងវិញ ប្រព័ន្ធស្រោចស្រពអាងទឹកកំពែង ស្ថិតក្នុងឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។

**យោង:** - ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ លើលិខិតលេខ ៧៩១២ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- លិខិតលេខ ០១៩ ធទឧ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ សូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមផ្តល់ជានាចំណាយជូនត្រឹមចំនួន ១ ១៤៩ ០០០ ០០០រៀល (មួយពាន់មួយរយសែសិបប្រាំបួនលានរៀលគត់) ដោយប្រើប្រាស់ឥណទានថវិកាជំពូក ២១ « គម្រោងវិនិយោគផ្ទាល់» សម្រាប់ឲ្យនាយកដ្ឋានវិស្វកម្មក្រសួងធនធានទឹកនិងឧតុនិយម អនុវត្តការងារជួសជុលឡើងវិញ ប្រព័ន្ធស្រោចស្រពអាងទឹកកំពែង ស្ថិតក្នុងឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ មានដូចខាងក្រោម:

| | | |
|---|---|---|
| - ជួសជុលទំនប់អាងទឹកកំពែង | ប្រវែង | ៤ ១១៥ម៉ែត្រ |
| - សាងសង់សំណង់ទ្វារទឹក ទ្វារ ១ លើទំនប់កំពែង | ចំនួន | ០១កន្លែង |
| - សាងសង់សំណង់លូមុខកាត់ ០,៨ម លើទំនប់កំពែង | ចំនួន | ០៣កន្លែង |

សេចក្តីដូចបានជម្រាបខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវការគោរពកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ
- សាលាខេត្តពោធិ៍សាត់
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តពោធិ៍សាត់
- នាយកដ្ឋានវិស្វកម្មក្រសួងធនធានទឹកនិងឧតុនិយម «ដើម្បីមុខការ»
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92. Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com